

# សៀវភៅដ៏ល្អបំផុត

Julie Romeis Sanders

Let's Read

The Asia Foundation



ព្រឹកនេះ អារីបើកទ្វារក្រោកចូលទៅក្នុងបន្ទប់បណ្ណាល័យដ៏ស្ងាត់ជ្រងំមួយដូចសព្វដង។ នាងតម្រង់ទៅរកសៀវភៅរៀបរាប់អំពីសត្វដែលនាងធ្លាប់អានញឹកញាប់។ នាងថែមទាំងធ្លាប់គិតចង់ឱ្យសៀវភៅទាំងនេះល្អជាងមុន។ ដូចជាគ្មានអ្វីថ្មីសោះ!



លោកគ្រូចាន់ ជាបណ្ណារក្ស លើកដៃស្វាគមន៍នាង។ អារីសួរថា៖ «តើថ្ងៃនេះមានសៀវភៅថ្មីទេលោកគ្រូ?» លោកគ្រូចាន់ក៏តបថា៖ «សៀវភៅថ្លៃៗណាស់ ហើយឆ្នាំនេះបណ្ណាល័យយើងពុំមានថវិកាគ្រប់គ្រាន់សម្រាប់ទិញថ្មីទេ។» អារីសួរបន្ត៖ «ចុះបើយើងបង្កើតសៀវភៅដោយខ្លួនឯង តើលោកគ្រូគិតយ៉ាងណាដែរ? ប្រហែលជាចំណាយមិនច្រើនទេមើលទៅ! ខ្ញុំចង់ផលិតសៀវភៅថ្មីដាក់ទីនេះ!» លោកគ្រូចាន់គិតបន្តិច រួចតបថា៖ «គំនិតល្អ! ប៉ុន្តែតើប្អូនដឹងទេថា ដើម្បីបង្កើតសៀវភៅ យើងត្រូវធ្វើដូចម្តេចខ្លះទេ?»



អារីគ្រវីក្បាល។ លោកគ្រូចាន់ក៏ពន្យល់ថា៖ «កិច្ចការនេះធំបន្តិច ប្អូនត្រូវការអ្នកចូលរួមជួយច្រើន ដូចជាអ្នកនិពន្ធ អ្នកគំនូរ និងអ្នកកែសម្រួល។» លោកគ្រូចាន់បន្តថា៖ «ប៉ុន្តែមិនអីទេ! ប្រសិនបើប្អូនរកបានអ្នកនិពន្ធ និងអ្នកគំនូរ លោកគ្រូមានមិត្តម្នាក់ដែលអាចជួយយើងកែសម្រួលអត្ថបទសៀវភៅបាន។» អារី ញញឹម រួចសំពះអរគុណលោកគ្រូចាន់ដោយត្រេកអរ។





ពេលរសៀល អារីបានប្រាប់គ្រប់គ្នាពីគម្រោងរបស់នាង។ មិត្តរួមថ្នាក់នាងបីនាក់ ចង់សាកល្បងសរសេរសៀវភៅ ឯមិត្តនាងម្នាក់ទៀតចង់គូររូប។ តាមផ្លូវទៅផ្ទះ អារីបានឆៀងចូលរកទិញរបស់ញ៉ាំបន្តិច ហើយនាងក៏ដឹងថាអ្នកលក់នោះធ្លាប់ជាអ្នកនិពន្ធម្នាក់ដែរ! យប់នោះ ឪពុកអារីបានសន្យាជួយគូររូបដាក់សៀវភៅមួយចំនួនឱ្យនាង ព្រោះគាត់ក៏ជាវិចិត្រករដ៏ចំណានម្នាក់ដែរ។



ថ្ងៃបន្ទាប់ អារីបាននាំអ្នកដែលព្រមជួយទៅកាន់បណ្ណាល័យ។ លោកគ្រូចាន់ និងស្ត្រីម្នាក់រាងខ្ពស់ដែលមានកាន់សៀវភៅកុំព្យូទ័រយួរដៃមួយ និងខ្មៅដៃពណ៌មួយចំនួនផង កំពុងរង់ចាំផ្លូវពួកគេ។ លោកគ្រូចាន់និយាយថា៖ «អារី! មកនេះ ចាំលោកគ្រូណែនាំឱ្យស្គាល់អ្នកកែសម្រួលសៀវភៅរបស់យើង។» «សួស្ដី អារី! មីងឈ្មោះចិន្ដា ជាអ្នកកែសម្រួលអត្ថបទ។ មីងឮថា ក្មួយចង់បង្កើតសៀវភៅមួយចំនួនសម្រាប់ដាក់បណ្ណាល័យមែនទេ?» «ចាស មែនហើយ! ពួកយើងត្រូវការសៀវភៅជាច្រើនបន្ថែមទៀត ពិសេសសៀវភៅស្ដីពីសត្វ។ តើមីងអាចជួយយើងបានដូចម្ដេច? ខ្ញុំរកបានអ្នកនិពន្ធ និងអ្នកគូរគំនូរហើយ។»



ចិន្តាក៏ពន្យល់ថា ការងាររបស់អ្នកកែសម្រួលគឺជួយអ្នកនិពន្ធឱ្យសរសេរសាច់រឿងបានល្អបំផុត។ អ្នកកែសម្រួលនឹងធ្វើឱ្យសាច់រឿងកាន់តែគួរឱ្យចាប់អារម្មណ៍ កំប្លែង ឬរន្ធត់តាមរយៈតួអង្គដែលធ្វើឱ្យក្មេងៗចង់អានម្តងហើយម្តងទៀត។ បន្ទាប់មកអ្នកកែសម្រួលសហការជាមួយអ្នករចនាទំព័រ និងអ្នកគូរគំនូរដោយធ្វើយ៉ាងណាឱ្យសាច់រឿងកាន់តែរស់រវើកតាមរយៈគំនូរ។ «ក្មួយមិនអាចមើលឃើញពីស្នាដៃមីងពេលសៀវភៅបោះពុម្ពហើយនោះទេ ព្រោះវាពិបាកយល់បន្តិច។ ប៉ុន្តែវាពិតជាសំខាន់ណាស់ ព្រោះគ្រប់សៀវភៅដែលបោះពុម្ពទាំងអស់សុទ្ធតែត្រូវការអ្នកកែសម្រួល។» អារីនិយាយ៖ «អស្ចារ្យមែន! ខ្ញុំមិនដែលដឹងសោះថា កិច្ចការនេះពាក់ព័ន្ធមនុស្សច្រើនបែប

នេះទេ។» «អារី! តើក្មួយអាចជួយមីងបានទេ? ក្មួយអាចជួយជ្រើសរើសរឿងណាដែលល្អបំផុត រួចយើងកែសម្រួលជាមួយគ្នា។ មីងនឹងឱ្យខ្មៅដៃពណ៌ក្រហមនេះទៅឯងដើម្បីធ្វើកិច្ចការនេះ។»



អារីចង់ធ្វើដោយអន្ទះសា។ សាច់រឿងខ្លះ វាកំប្លែង និងគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែសាច់រឿងខ្លះទៀត ហាក់គួរឱ្យធុញទ្រាន់ ឯរឿងដទៃទៀតនោះមិនមាននិយាយអំពីសត្វនោះទេ។ មីងចិន្តាបានរំឭកអារីថា ការងារនាងគឺត្រូវកែសម្រួលសាច់រឿងឱ្យបានល្អជាងមុន។ ថ្វីបើអារីចូលចិត្តសត្វ ប៉ុន្តែក្មេងដទៃទៀតអាចចូលចិត្តអ្វីផ្សេងពីនេះ។ ដូច្នេះសៀវភៅទាំងនេះគឺសម្រាប់ក្មេងៗគ្រប់គ្នា មិនមែនសម្រាប់តែអារីម្នាក់ទេ។ អារីប្រើខ្មៅដៃរបស់នាងផ្តល់យោបល់យ៉ាងម៉ត់ចត់។ មីងចិន្តាបន្ថែមគំនិតផ្សេងទៀតដោយប្រើខ្មៅដៃពណ៌ខៀវ។ បន្ទាប់មកពួកគេក៏ប្រគល់អត្ថបទព្រាងដំបូងទៅឱ្យអ្នកនិពន្ធដើម្បីកែសម្រួលឡើងវិញ។ ទីបំផុតសាច់រឿងមានខ្លឹមសារល្អឥតខ្ចោះ!



ឥឡូវនេះ សៀវភៅទាំងនេះត្រូវការរូបភាពលម្អ។ មីងចិន្តា ណែនាំថា អ្នករចនាទំព័រនឹងប្រើកុំព្យូទ័រដើម្បីបញ្ចូលអត្ថបទ និង រូបភាព។ អ្នកកែសម្រួលនឹងពិនិត្យលើការរចនាយ៉ាងល្អិតល្អន់ ដើម្បីធានាថាត្រឹមត្រូវ និងមិនមានកំហុសឆ្គង។ អារីមើល ឪពុកនាងគូសព្រាងជាគំនិតសម្រាប់រូបភាពក្នុងសៀវភៅយ៉ាង ជក់ចិត្ត។ មិនយូរប៉ុន្មានគំនូសព្រាងទាំងនោះបានប្រែក្លាយ ទៅជាគំនូរដ៏ស្រស់ស្អាតខុសៗគ្នាតាមទំព័រនីមួយៗ។



បន្ទាប់ពីការរចនារួចរាល់ អារីសួរថា៖ «ឥឡូវរឿងទាំងនេះអាចបោះពុម្ពបានហើយតើមែនទេ?» កិច្ចការនេះត្រូវប្រើពេលយូរជាងការរំពឹងទុករបស់នាង ហើយមានការងារច្រើនណាស់!

ចិន្តានិយាយដោយញញឹមថា៖ «អារី! ដល់ពេលហើយ! ថ្ងៃនេះយើងនឹងបញ្ជូនឯកសាររបស់យើងយកទៅកន្លែងបោះពុម្ព។ សៀវភៅនឹងបោះពុម្ពរួចរាល់ក្នុងរយៈពេលពីរបីសប្តាហ៍ទៀត!»



អារីរង់ចាំដោយអន្ទះសា។ នាងចង់ដឹងថាតើសៀវភៅទាំងនោះល្អដែរឬទេ? តើគេចង់អានវាដែរឬទេ? ទីបំផុត នាងឃើញរថយន្តមួយគ្រឿងបើកបរសំដៅមកឈប់នៅមុខបណ្ណាល័យ។ អារីស្រែក៖ «សៀវភៅមកដល់ហើយ!»



មនុស្សម្នាជុំគ្នានៅបណ្ណាល័យ។ មីងចិន្តាបានបើកប្រអប់ទីមួយរួចហុចសៀវភៅមួយក្បាលឱ្យអារី។ «អបអរសាទរ អ្នកកែសម្រួលវ័យក្មេង! ក្មួយធ្វើបានហើយ!» អារីអង្គុយចុះ ហើយចាប់ផ្តើមអានសៀវភៅ។ មិនយូរប៉ុន្មាន អ្នកដទៃទៀតក៏ចូលរួមអានជាមួយនាងដែរ។



ចាប់ពីពេលនេះទៅ រាល់ពេលអារីបើកទ្វារបណ្ណាល័យ បន្ទប់នេះលែងស្ងាត់ជ្រងំទៀតហើយ។ នាងដើរកាត់ទូធ្នើរដាក់សៀវភៅដើម្បីរកសៀវភៅណាដែលនាងចង់អាន។

Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*សៀវភៅដ៏ល្អបំផុត (The Best Book)*, Author: Julie Romeis Sanders. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/